ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំទី ១០ លេខ ៤

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC



កសវ

Work Activities

ប្រចាំខែមេសា ឆ្នាំ២០១៧



# មាតិកា

| ល.រ | បរិយាយ | លេខទំព័រ |
|---|---|---|


I- កិច្ចប្រជុំជំនាញបច្ចេកទេស

- សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ១-៣

II- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមីនា ឆ្នាំ២០១៧ ៤-១១

III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ឃឹម ឈុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១៧ ១២-១៥

# សេចក្តីព្រាងគោលនយោបាយជាតិស្តីពី

## ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥

កាលពីថ្ងៃទី០៥ និងថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ឯកឧត្តម **ស៊ា ម៉ៅ** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យ ពិភាក្សាលើ**សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥** ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។



រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងផ្តោតការយកចិត្តយ៉ាងខ្លាំងលើគ្រប់វិស័យជាពិសេសការអភិវឌ្ឍវិស័យការងារ រួមទាំងការបង្កើតការងារ ការពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ព្រមទាំងជំរុញការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឲ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ការលើកស្ទួយជីវភាពប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយចីរភាព ដូចជាបានរំលេចឡើងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ តាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ក៏បានបង្ហាញនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដែលជាភស្តុតាងច្បាស់លាស់ក្នុងបរិបទនៃការបង្កើតការងារ ដើម្បីបង្កើនល្បឿនកំណើនសេដ្ឋកិច្ច ហើយផែនការយុទ្ធសាស្ត្រនេះ ក៏បានបែងចែកនូវសកម្មភាពសំខាន់ៗមួយចំនួនសម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសទាក់ទងនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គឺជាកត្តាមិនអាចខ្វះបានក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងជំរុញឲ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ជំនាញបច្ចេកទេសជាមួយសមត្ថភាពពិតប្រាកដ ដើម្បីក្លាយខ្លួនជាពលករជំនាញ អ្នកបច្ចេកទេស ព្រមទាំងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ។ នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយបាយជាតិធំៗមួយចំនួនដែលក្នុងនោះរួមមាន “គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥” និង “គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥” ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ឧស្សាហកម្ម និងការបង្កើតការងារសមរម្យ ព្រមទាំងធានាគុណភាព និងផលិតភាពខ្ពស់របស់កម្លាំងពលកម្មដែលអាចប្រកួតប្រជែងប្រសើរជាងមុនជាមួយបណ្តាប្រទេសក្នុងតំបន់។ ដើម្បីចូលរួមសម្រេចគោលដៅរបស់គោលនយោបាយជាតិដែលបានដាក់ចេញខាងលើនេះ “គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ” ចាំបាច់ត្រូវរៀបចំឡើងដោយកំណត់នូវចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្រ្តឲ្យបានច្បាស់លាស់ក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពខ្ពស់ សមត្ថភាព និងជំរុញឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម នាពេលបច្ចុប្បន្ន និងអនាគត។

នៅក្នុងអាស៊ាន ការអភិវឌ្ឍជំនាញមានការរីកចម្រើនយ៉ាងឆាប់រហ័សដោយសារមានការយល់ឃើញថា វាជាកត្តាមួយដ៏ចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ច។ ការផ្លាស់ប្តូរត្រូវបានគាំទ្រតាមរយៈគោលនយោបាយក្នុងការអភិវឌ្ឍជំនាញដែលជាទូទៅផ្អែកលើតម្រូវការ និងបានដាក់បញ្ចូលទៅគ្រប់ក្រសួង ព្រមទាំងស្ថាប័នពាក់ព័ន្ធទាំងអស់ដែលផ្តល់ការបណ្តុះបណ្តាល។ នៅតាមបណ្តាលប្រទេសមួយចំនួន ការអប់រំបណ្តុះបណ្តាល និងវជ្ជាជីវៈ ត្រូវបានពង្រីក និងក្លាយជាអាជ្ញាធរឬភ្នាក់ងារឯករាជ្យក្នុងរដ្ឋាភិបាល ព្រមទាំងបានបង្កើតស្តង់ដា



សម្រាប់វិស័យអាទិភាពមួយចំនួន មិនមែនត្រឹមតែបច្ចេកវិទ្យានោះទេ ប៉ុន្តែសម្រាប់សុខាភិបាល និងជំនាញអាជីវកម្ម ជាពិសេសជំនាញដែលផ្អែកលើប្រព័ន្ធកុំព្យូទ័រផងដែរ។ អាស៊ានក៏មានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រឲ្យមានស្តង់ដាជំនាញក្នុងតំបន់រួមគ្នា ហើយអត្ថប្រយោជន៍ទាំងនេះត្រូវបានមើលឃើញថា មាននៅក្នុងផ្នែកបដិសណ្ឋានកិច្ច ក៏ដូចជាអាជីវកម្មតាមបែបប្រពៃណីផងដែរ(១)។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥។

# II- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមីនា ឆ្នាំ២០១៧



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា **ប្រចាំខែមីនា ឆ្នាំ២០១៧** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ ក្រោមអធិបតីភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែមីនាឆ្នាំ២០១៧សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,០% ធៀបនឹងខែមុន និងកើនឡើង៤,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ការដឹកជញ្ជូន: | +៦% | ប្រេងសាំង: | +១៥,៤% |
| ម្ហូបអាហារ: | +៥,៧% | ប្រេងម៉ាស៊ូត: | +១២,៥% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +៣,៩% | បន្លែ: | +១១,៨% |
| ភោជនីយដ្ឋាន: | +៣,៦% | ត្រីស្រស់: | +១០,១% |
| សំលៀកបំពាក់ និងស្បែកជើង: | +៣,៦% | ផ្លែឈើ: | +៥,២% |
| ការកំសាន្ត និងវប្បធម៌: | +២,៦% | សាច់មាន់: | +៤,៥% |
| សុខាភិបាល: | +២,២% | សាច់គោ: | +៤% |
| ទំនិញ និងសេវាកម្មផ្សេងៗ: | +១,៨% | សាច់ជ្រូក: | +៣,៥% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +០,៨% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៥–២០១៧

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា P | ឧសភា P | មិថុនា P | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,២% | ៤,០% | ៣,៩% | ៣,៩% | | | | | | | |
| | មុន | ០,៣% | ០,១% | ០,០% | ០,៧% | ០,៥% | ០,៧% | | | | | | | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,១% | ០,២% | ០,៦% | ០,៣% | ០,២% | ០% | -០,២% | ០,២% | |

P: តួលេខខែ មេសា ឧសភា និងមិថុនា ឆ្នាំ២០១៧ ជាតួលេខព្យាករ (តាមវិធីសាស្រ្ត DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ )Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១១.. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់







តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | មីនា ២០១៧ | កុម្ភៈ ២០១៧ | មីនា ២០១៦ | *ប្រភេទ* | មីនា ២០១៧ | កុម្ភៈ ២០១៧ | មីនា ២០១៦ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០០៥៛/១$ | ៤០០៤៛/១$ | ៤០០៦៛/១$ | **បាត/ដុល្លារ** | ៣៤,៤៩បាត/១$ | ៣៤,៨៥បាត/១$ | ៣៥,២៣បាត/១$ |
| **៛/បាត** | ១១៦៛/១បាត | ១១៥៛/១បាត | ១១៤៛/១បាត | **ដុង/ដុល្លារ** | ២២៧៦៥ដុង១$ | ២២៧៧៧ដុង១$ | ២២២២៨ដុង/១$ |
| **៛/ដុង** | ០,១៧៦៛/១ដុង | ០,១៧៦៛/១ដុង | ០,១៨០៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែមីនា ឆ្នាំ ២០១៧ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៧៨៧,២ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៤៤៦,៨ លានដុល្លារ ( *មធ្យមប្រចាំខែ១០៧% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន១៧៨៧,២ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៤៤៦,៨លានដុល្លារ ( *មធ្យមប្រចាំខែ ១១០% នៃផែនការ*) និងមិនមានចំណូលមូលធនទេ(តាមតួលេខរតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៥–២០១៧ (ប៊ីលានរៀល)




- ➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិកើនឡើង ២៥,៦% និងកើនឡើង១០,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១៥៩០,៦ប៊ីលានរៀលកើនឡើង២១,៦%ធៀបនឹងខែមុន និងកើនឡើង៦,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ រតនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន១៩៦,៦ប៊ីលានរៀល កើនឡើង៧១,៤% ធៀបនឹងខែមុន និងកើនឡើង៧១,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ**<br>(ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ**<br>(តាមតួលេខ រតនាគារជាតិ)<br>(ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➤ ពន្ធ និងអាករគយ: +៤,៩%<br>(អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (-១០,២%) | ➤កាស៊ីណូ : -២៣,១% | (-០,២%) |
| ➤ ចំណូលពន្ធដារ: +១៣៨,៨%<br>(អគ្គនាយកដ្ឋានពន្ធដារ) | (+១៦,៧%) | ➤អាជ្ញាបណ្ណក្នុងស្រុក : +១៧០២,៨% | (+៩៨៦,៦%) |
| | | ➤ នេសាទ: +២៧៧,៤% | (-៦,១%) |
| | | ➤សម្បទានរ៉ែ: +៣៤៣,២% | (+៦៨០,៦%) |
| | | ➤ អាកាសចរណ៍ស៊ីវិល: -៧៧% | (-២០,៦%) |
| | | ➤ផលទុននៃសកម្មភាពទេសចរណ៍: +៤២,២% | (+១៩២,៦%) |
| | | ➤អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ): +៩៥,៩% | (+៥២,១%) |
| | | ➤ការត្រួតពិនិត្យគុណភាពផលិតផល: +៥៤% | (-៤៤,៦%) |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ១១៤៦,៣ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ២៨៦,៦លានដុល្លារ (*មធ្យមប្រចាំខែ ៦៣% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន ៩៤០,៧ប៊ីលានរៀល (*មធ្យមប្រចាំខែ ៦៨% នៃផែនការ*) និងចំណាយមូលធនមានចំនួន២០៥,៦ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➤ចំណាយថវិកាជាតិកើនឡើង២៩,១% ធៀបនឹងខែមុននិងកើនឡើង៦៣,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង១១,៣% ធៀបនឹងខែមុននិងកើនឡើង៥៨,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេកចំនួន ៦៤០,៩ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១៦០,២លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៥–២០១៧
(ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែមីនា ឆ្នាំ២០១៧មានលក្ខណៈដូចខាងក្រោម:

➤រូបិយវត្ថុ$M_2$ មានចំនួន ៦០៥៤៧ប៊ីលានរៀល កើនឡើង១,៦%ធៀបនឹងខែមុន និងកើនឡើង១៨,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង $M_2$** ក្នុងខែនេះ ជារួម បណ្តាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ០,៦% និងប្រាក់បញ្ញើជារូបិយបណ្ណ៣,១%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែមីនា ឆ្នាំ២០១៧



➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៥,៥% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ១១,៣% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៧

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៦,៧% | ១៦,៦% | ១៥,៥% | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៣% | ១១,៤% | ១១,៣% | | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែមីនា២០១៧: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢ **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៧១៥៣លានដុល្លារ កើនឡើង២,៩%ធៀបនឹងខែមុន និងកើនឡើង៣២,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ២១០៨៦ប៊ីលានរៀល កើនឡើង ១,៣% ធៀបនឹងខែមុន និងកើនឡើង៣៤,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *មីនា២០១៧* | *កុម្ភៈ២០១៧* | *មីនា២០១៦* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ( ប៊ីលានរៀល ) | ៥៧៨៣៤ | ៥៨២៤៤ | ៥០៨៧៥ |
| ក្នុងនោះ ជារៀល | | ៩៤៨ | ៦៧០ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ( ប៊ីលានរៀល ) | | ១៣២៥២ | ១៣០៤៩ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | | ៦,៨០% | ៦,៥១% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | | ១៦,២០% | ១៦,៣៦% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | | ៤,៤៤% | ៤,៤៤% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | | ១១,៦៩% | ១១,១២% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថាកសិករ | | ២៣,៤% | ៣១,២% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | | ២៨,៨% | ២៩,៤% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | | ២២,៨% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែមីនាឆ្នាំ២០១៧ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៤៦ពាន់តោន ថយចុះ៩% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល:**

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៦០០,៤១GWHមានការកើនឡើង៥%ធៀបនឹងខែមុន និងកើនឡើង៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន៩៥,៩៨GWHមានការកើនឡើង១៣៥%ធៀបនឹងខែមុន និងកើនឡើង៣៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន៣៣៥,២៥GWHមានការថយចុះ៥% ធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង៣៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម:**

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៥៦៣លានដុល្លារមានការកើនឡើង៣%ធៀបនឹងខែមុន និងកើនឡើង៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន —មីនា២០១៧ | ចំនួន—កុម្ភៈ២០១៧ | ចំនួន—មីនា២០១៦ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | | ៤ | ១៤ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | | ១៥៨៥ | ១៤៩០ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២០ | ២១ | ៧៤ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១៨ | ៣៤ | ៦២ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៩៣០,៦ពាន់ម$^2$កើនឡើង១៤%ធៀបនឹងខែមុន ប៉ុន្តែថយចុះ៥៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៥៥៣,៥លានដុល្លារថយចុះ៣%ធៀបនឹងខែមុន និងថយចុះ២៦%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម$^2$ —មីនា២០១៧ | ពាន់ម$^2$ —កុម្ភៈ២០១៧ | ពាន់ម$^2$ —មីនា២០១៦ |
|---|---|---|---|
| ▪ លំនៅឋាន | ៦៨៧,៦ | ៤៩៤,៤ | ៣៣២,៦ |
| ▪ ឧស្សាហកម្ម | ៨២,៩ | ២០៤,៨ | ៨៧,២ |
| ▪ពាណិជ្ជកម្ម | ៦៣,៣ | ១៧,២ | ១៧៨៩,៦ |
| ▪ ទេសចរណ៍ | ៩៤,៦ | ៩៦,៩ | ២២,១ |
| ▪ផ្សេងៗ | ០,១ | ០,០ | ១,៦ |
| អនុញ្ញាតសរុប | ៩៣០,៦ | ៨១៨ | ២២៣៣,៨ |

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់—មីនា ២០១៧ | នាក់—កុម្ភៈ ២០១៧ | នាក់—មីនា ២០១៦ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ១១០៨ | ២២៩៣ | ១០៣៧ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារនិងក្រុមហ៊ុន | ១២៤៨៧ | ១២០០៣ | ៨៥០២ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៩៩៦៦ | ៩៣៣១ | ៦៥៤៨ |
| អ្នកទទួលបានការងារក្រៅប្រទេស | ២៥២១ | ២៦៧២ | ១៩៥៤ |

### ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | មីនា២០១៧ | កុម្ភៈ២០១៧ | មីនា២០១៦ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៩១ | ៤២០ | ៤០,១ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៥៥ | ៧០ | ០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៣៦ (៨) | ៣៤៩ (២៦៣) | ៤០,១ (៥) |
| វិស័យទេសចរណ៍ | ០ | ០ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ០ | ០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១៣ | ១៨ | ៩ |
| បង្កើតការងារ (ពាន់នាក់) | ១៣ | ២៨ | ១៦,១ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៩១៥,១ពាន់តោនកើនឡើង៣៥%ធៀបនឹងខែមុន និងកើនឡើង១៦%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៤.៥.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:+១៦% | (+១៨%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:+២៧% | (-៨៦%) |
| ▪ កំពង់ផែកំពង់សោម:+៤៧% | (+២៣%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +១៥% | (+២៦%) |

### ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ២០,១ | ៣០% | ៣៧% |
| ក្នុងនោះទទួល | ២,២ | -៤% | ៣% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១២៨ | ១៣% | ៨% |
| ក្នុងនោះទទួល | ៥៧ | ២៣% | ១២% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២៧០៥ | ១៣% | -៤% |
| ក្នុងនោះហៅចូល | ៧៧៣,៧ | ១១% | ១១% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៧៨១២,៣ | -២៧% | -៣០% |
| ក្នុងនោះហៅចូល | ៧៧៤៥,៥ | -២៧% | -៣១% |

### ➢ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %∆ ធៀបនឹងខែមុន | %∆ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២៥ | -១២% | ៣១% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៤៨ | ០% | ២៣% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៦៤១,៣ | -៧% | ១៨% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | | | |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា<br>✓ តាមផ្លូវអាកាស<br>✓ តាមផ្លូវគោក និងទឹក | | | |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែមីនា ឆ្នាំ២០១៧ មានចំនួន ៤៧៦៣,៣ប៊ីលានរៀល (ស្មើនឹង១១៩០,៨លានដុល្លារ ស.រ.អា.)កើនឡើង១២,៣%ធៀបនឹងខែមុន និងកើនឡើង៨,៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ□ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +៦,២% | +៤០,១% | រថយន្តសរុប (ប៊ី.ល.រ) | +២៣,៥% | -២៨,១% |
| ប្រេងម៉ាស៊ូត | -១៤,៨% | +៣% | រថយន្តសរុប (គ្រឿង) | +៣,១% | -២៩% |
| ឧស្ម័ន | -៣,៥% | -៦,៤% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៤៣,៦% | -២៦,៩% |
| អគ្គិសនីនាំចូល | +១% | -២០% | ម៉ូតូ (គ្រឿង) | -១,៦% | -៣២,៧% |
| ដែកសំណង់ | -២០,៧% | +១៤,១% | អង្ករ | +២៣,២% | -៩៣% |
| ស៊ីម៉ង់ត៍ | +១០៥,៣% | +៨៨,៥% | ផ្លែឈើនិងបន្លែ | -៥,៥% | -៣២,១% |
| គ្រឿងអេឡិចត្រូនិក | +៥៤,៩% | +២៨,៤% | ជីនិងថ្នាំកសិកម្ម | -២៦,៣% | +៤៥% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៥០,៨% | +១១,៩% |

➡ **ការនាំចេញ** ខែមីនា ឆ្នាំ២០១៧ មានចំនួន **៣៦៩៦,៤**ប៊ីលានរៀល ស្មើនឹង ៩២៤,១លានដុល្លារ ស.រ.អា. (**៧៧,៦**% នៃការនាំចូល)កើនឡើង១០,៩%ធៀបនឹងខែមុន និងកើនឡើង២២,៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +១៦៦,៩% | +១៥៣% | ផលិតផលនេសាទ | +២០៨,១% | +៨៣,១% |
| វាយនភណ្ឌនិងស្បែកជើង | +៤% | +១៧,៦% | កៅស៊ូ | -២៩,៣% | -៣០,៨% |
| អង្ករ | +៨,៧% | -០,៣% | | | |

## ៦. បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមីនា ឆ្នាំ២០១៧នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃប្រេងសាំង | +០,១% | +១៥,៤% | — |
| ២ | ថ្លៃបន្លែ | -០,៩% | +១១,៨% | — |
| ៣ | ថ្លៃត្រីស្រស់ | -០,១% | +១០,១% | — |
| ៤ | អ្នកទទួលការងារធ្វើថ្មីតាមរយៈក្រសួងការងារនិងក្រុមហ៊ុន ក្នុងប្រទេស | +៤% | +៤៧% | — |

## ៧) សេចក្តីសន្និដ្ឋាន

១) ការនាំចេញអង្ករមានកម្រិតទាប បើធៀបនឹងផែនការនាំចេញ (១លានតោនក្នុងមួយឆ្នាំ )។ នៅឆ្នាំ២០១៥ កម្ពុជានាំចេញបានប្រហែល ៥២ម៉ឺនតោន និងឆ្នាំ២០១៦-៥៣ម៉ឺនតោន។ បញ្ហាប្រឈមចម្បងៗនៃវិស័យនេះ មាន (i) របាំងពាណិជ្ជកម្មពីប្រទេសនាំចូល ដែលអង្ករកម្ពុជាពិបាកឆ្លើយតបនឹងការតម្រូវស្តង់ដារបស់ប្រទេសទាំងនោះ។ ឧទាហរណ៍ បច្ចុប្បន្ននេះ សហគមន៍អឺរ៉ុបតម្រូវឲ្យកាត់បន្ថយសារធាតុ Tricyclazole ក្នុងអង្ករឲ្យស្ថិតក្នុងលីមីតដែលគេចង់បាន(ថយចុះពី0,១មីលីក្រាម/១គកអង្ករ មកត្រឹម0,0១មីលីក្រាម/គកអង្ករ) និងចាប់ផ្តើមអនុវត្តនាខែកក្កដា ឆ្នាំ២០១៧នេះ។ បញ្ហានេះ ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម គួរធ្វើការចចារអំពីលទ្ធភាពពន្យាពេលសិន ពីព្រោះកសិករយើងអាចអនុវត្តមិនបានតាមកាលកំណត់នេះ។ (ii) ខ្វះម៉ាស៊ីនសម្ងួត និងឃ្លាំងស្តុក។ (iii) រងការប្រកួតប្រជែងខ្លាំងពីសំណាក់ប្រទេសនាំចេញអង្ករដូចគ្នា ។ល។

២) មានការថយចុះខ្លាំងនៃការចិញ្ចឹមសត្វគោក្របី ដែលធ្វើឲ្យមានឱនភាពនៃការផ្គត់ផ្គង់ផលិតផលសាច់ធ្វើឲ្យថ្លៃសាច់កើនឡើង និងជះឥទ្ធិពលលើសន្ទស្សន៍ថ្លៃម្ហូបអាហារជារួម។

៣) កម្ពុជាត្រូវជំរុញចលនាសហគមន៍កសិកម្ម ឲ្យបានទូលំទូលាយ ក្នុងគោលបំណងលើកកម្ពស់កិច្ចសហការបានល្អរវាង ផលិតករនិងផលិតករ ផលិតករនិងទីផ្សារ និងពង្រីកខ្នាតផលិតកម្មឲ្យបានធំទូលាយ ព្រោះផលិតកម្មខ្នាតតូចមិនមានលទ្ធភាពប្រកួតប្រជែងលើទីផ្សារ ដូចផលិតកម្មខ្នាតធំដែលមានថ្លៃដើមទាបជាង មាននិរន្តរភាពជាង និងរចនាសម្ព័ន្ធល្អជាង។

៤) បន្តពង្រឹង និងពង្រីកចលនាភូមិមួយ ផលិតផលមួយ ឲ្យដល់គ្រប់មូលដ្ឋាន និងចេញជាការអនុវត្ត ដែលមកដល់ពេលនេះ មានតែជាគោលការណ៍ និងរចនាសម្ព័ន្ធត្រឹមថ្នាក់លើប៉ុណ្ណោះ។

៥) ក្នុងឆ្នាំ ២០១៧នេះ មានការជំរុញការប្រើប្រាស់សៀវភៅបញ្ជីការគណនេយ្យឲ្យបានទូលំទូលាយសម្រាប់អ្នកប្រកបរបរ ក្នុងគោលដៅលើកកម្ពស់តម្លាភាព និងប្រសិទ្ធភាពនៃការប្រមូលពន្ធ (របបស្វ័យប្រកាស)។

៦) សំណង់អនុញ្ញាត នាបីខែឆ្នាំ២០១៧ នេះ មានការថយចុះគួរឲ្យចាប់អារម្មណ៍បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៦ ប៉ុន្តែការថយចុះនេះ ជារួមកើតឡើងតែទៅលើសំណង់ធំៗប៉ុណ្ណោះ (ផ្ទៃក្រឡាលើសពី ៣000ម$^{២}$) ចំណែកសំណង់ខ្នាតតូច នៅតែរក្សាកំណើន ជាពិសេសនៅតាមបណ្តាខេត្ត៕

# III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១៧

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៣/០៤/១៧ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ មហាវិថីសម្តេច **ហ៊ុន សែន** ទីក្រុងរណបតំបន់ជើងឯក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ |
| ២ | ០៣/០៤/១៧ ម៉ោង១៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីជប់លៀងបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ |
| ៣ | ០៤/០៤/១៧ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានសាងសង់កីឡាដ្ឋានធំ និងសម្ពោធដាក់ឲ្យប្រើប្រាស់មណ្ឌលកីឡាក្នុងសាល-មណ្ឌលកីឡាហែលទឹកនៃពហុកីឡាដ្ឋានជាតិមរតកតេជោ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ |
| ៤ | ០៤/០៤/១៧ ម៉ោង១៣:៣០នាទី | ចូលរួមកិច្ចប្រជុំ ប្រកាសប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** អនុប្រធានគណបក្សប្រជាជនកម្ពុជា និងជាប្រធានគណៈប្រចាំការគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ៥ | ០៥/០៤/១៧ ម៉ោង១៥:០០នាទី | ចូលរួមកិច្ចប្រជុំគណៈកម្មាធិការគណបក្សទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៦/០៤/១៧ ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធបើកឲ្យប្រើប្រាសជាផ្លូវការកំណាត់ផ្លូវជាតិលេខ៦ ប្រវែង៤០,៤៩២ គ.ម ចាប់ពីសង្កាត់ព្រែកលៀប (គ.ម៦+០០៨) ដល់ឃុំសំបួរ (គ.ម៤៦+៥០០) ក្រោមហិរញ្ញប្បទានសម្បទាន ពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ០៧/០៤/១៧<br>ម៉ោង១៥:០០នាទី | ចូលរួមក្នុងពិធីសូត្រមន្តចម្រើនព្រះបរិត្ត និងពិធីជួបជុំហូបបាយ សំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងឱកាសអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ ២៥៦១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង **លោកជំទាវ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ០៩/០៤/១៧<br>ម៉ោង០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយសមាជិក សមាជិកាគណបក្សនៅតាមសាខាគណបក្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណបក្សប្រជាជនកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៩ | ១០/០៤/១៧<br>ម៉ោង១៥:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទូទាំងប្រទេសប្រចាំឆ្នាំ២០១៦-២០១៧ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០១៧-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១០ | ១១/០៤/១៧<br>ម៉ោង០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីផ្សព្វផ្សាយលើកដំបូងនូវសៀវភៅជាខេមរភាសាស្តីពី "**ស៊ី ជិនភីង ៖ អភិបាលកិច្ចប្រទេសចិន**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១១ | ១៧/០៤/១៧<br>ម៉ោង១០:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ផៃខ សុទិដ្ឋានោ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ១៨/០៤/១៧<br>ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំក្តាញ់ ឃុំតាំងយ៉ាប និងឃុំកំពង់រាប នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ១៨/០៤/១៧<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំអង្កាញ់នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | ១៩/០៤/១៧<br>ម៉ោង១៤:០០នាទី | អមឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ចូលរួមដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **ពិត តាំងសាន** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៅគេហដ្ឋាននៃសព។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៥ | **២០/០៤/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ-ជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជូនដល់និស្សិតសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៦ | **២០/០៤/១៧ ម៉ោង១៥:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរកីឡាការិនី **អ៊ុក ស្រីមុំ** ជ័យលាភីមេដាយមាសកីឡាប៉េតង់ជើងឯកពិភពលោក ឆ្នាំ២០១៧ នៅប្រទេសបែលហ្ស៊ិក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៧ | **២០/០៤/១៧ ម៉ោង១៧:៤៥នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **តិច សំណាង** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | **២១/០៤/១៧ ម៉ោង១៥:០០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំព្រៃកប្បាស នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | **២៣/០៤/១៧ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយប្រធាន អនុប្រធានសាខាគណបក្ស សហជីព កម្មករនិយោជិត និងតំណាងមន្ត្រីរាជការ គ្រូបង្រៀន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ២០ | **២៣/០៤/១៧ ម៉ោង១៣:៣០នាទី** | ចូលរួមជាអធិបតី ក្នុងពិធីសំណេះសំណាលជាមួយប្រធាន និងអនុប្រធានក្រុមបក្សឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្នាក់ការគណបក្សឃុំ។ |
| ២១ | **២៤/០៤/១៧ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំព្រៃល្វានៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២២ | **២៦/០៤/១៧ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំ ០៦ នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ២៣ | **២៧/០៤/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់វិញ្ញាបនបត្រ សញ្ញាបត្រ ជូនសិក្ខាកាមវិជ្ជាជីវៈ និងនិស្សិតថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិត សាកលវិទ្យាល័យ ធនធានមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ២៤ | **២៧/០៤/១៧ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាននិងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែមីនា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៥ | **២៧/០៤/១៧ ម៉ោង១៧:៣០ នាទី** | ប្រជុំការងារជាមួយលោក Eric DELOBEL CEO ក្រុមហ៊ុន SCA នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៦ | **២៩/០៤/១៧ ម៉ោង០៨:០០នាទី** | ចូលរួមកិច្ចប្រជុំ សំណេះសំណាលជាមួយគណៈកម្មាធិការគណបក្សមូលដ្ឋានសាខាបក្សភូមិ និងបេក្ខជនក្រុមប្រឹក្សាឃុំអាណត្តិទី៤ នៃស្រុកព្រៃកប្បាស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការរដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅការិយាល័យសហភាពសហព័ន្ធយុវជនស្រុកព្រៃកប្បាស។ |
| ២៧ | **៣០/០៤/១៧ ម៉ោង០៩:០០នាទី** | ចូលរួមជាអធិបតី ក្នុងពិធីសំណេះសំណាលជាមួយប្រធាន និងអនុប្រធានក្រុមបក្សឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្នាក់ការគណបក្សឃុំ។ |
| ២៨ | **៣០/០៤/១៧ ម៉ោង១៤:០០នាទី** | ចូលរួមជាអធិបតី ក្នុងពិធីសំណេះសំណាលជាមួយប្រធាន និងអនុប្រធានក្រុមបក្សឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្នាក់ការគណបក្សឃុំ។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in